# សេចក្តីសង្ខេបអំពីកម្មវិធីអាហារូបករណ៍ដែលផ្តល់ឱកាសអាចទារថ្លៃបង់ពន្ធមកវិញ
## (Opportunity Scholarship Tax Credit Program)

**ការបង្កើតឡើង៖** កម្មវិធីអាហារូបករណ៍ដែលផ្តល់ឱកាសអាចទារថ្លៃបង់ពន្ធមកវិញ ផ្តល់អាហារូបករណ៍ដល់សិស្សានុសិស្សដែលមានសិទ្ធិអាចទទួល ដែលចង់ទៅរៀននៅ សាលារដ្ឋណាដែលចូលរួមក្នុងកម្មវិធីនេះ ឬសាលាឯកជន តាមបំណងនៃការជ្រើសរើសរបស់ពួកគេ។

**សិទ្ធិដែលអាចទទួល៖** កម្មវិធីអាហារូបករណ៍ដែលផ្តល់ឱកាសអាចទារថ្លៃបង់ពន្ធមកវិញ អនុញ្ញាតឲ្យក្រុមហ៊ុនធ្វើវិភាគទានទៅឲ្យអង្គការដែលផ្តល់អាហារូបករណ៍ ដែលផ្តល់ថវិកាដល់សិស្សានុសិស្សណាដែលមានសិទ្ធិអាចទទួល ដែលរស់នៅក្នុងព្រំដែនដែលត្រូវទៅរៀននៅសាលាដែលអន់ខ្សោយ។ «សាលាដែលអន់ខ្សោយ» បានឲ្យនិយមន័យដល់ សាលាបឋមសិក្សា ឬសាលាមធ្យមសិក្សា នៅក្នុងរដ្ឋពិនស៊ីលវេញ៉ា ដែលមានចំណាត់ថ្នាក់ក្រោម១៥ភាគរយ ក្នុងចំណោមសាលាបឋមសិក្សា ឬសាលាមធ្យមសិក្សា ទាំងអស់ ដោយយោងទៅលើពិន្ទុសរុបនៃ គណិតវិទ្យា និងការអាន នៃការប្រឡង PSSA ក្នុងពេលថ្មីៗនេះ។ លក្ខខណ្ឌនេះមិនរួមបញ្ចូល សាលាឆាធ័រ សាលាឆាធ័រដែលរៀនតាមកុំព្យូទ័រ ឬសាលាបច្ចេកវិទ្យា នោះទេ។ សិស្សានុសិស្ស (រួមទាំងសិស្សដែលចូលរៀនថ្នាក់មត្តេយ្យ) រស់នៅក្នុងព្រំដែននៃសាលាអន់ខ្សោយ អាចមានសិទ្ធិដើម្បីដាក់ពាក្យស្នើសុំអាហារូបករណ៍។ សិស្សានុសិស្សដែលមានសិទ្ធិ អាចរួមទាំងក្មេងដែលរស់នៅក្នុងព្រំដែននៃសាលាអន់ខ្សោយ ដែល៖

- រៀននៅសាលាអន់ខ្សោយ នាពេលបច្ចុប្បន្ន
- បានចុះឈ្មោះរៀននៅសាលាឯកជន នាពេលបច្ចុប្បន្ន
- ធ្លាប់រៀននៅផ្ទះ កាលពីមុន ឬ
- ធ្លាប់រៀននៅសាលាឆាធ័រ ឬសាលាឆាធ័រដែលរៀនតាមកុំព្យូទ័រ កាលពីមុន។

សិស្សានុសិស្សដែលមានសិទ្ធិ បានឲ្យនិយមន័យដល់ ក្មេងដែលគ្រប់អាយុចូលរៀន រស់នៅក្នុងព្រំដែននៃសាលាអន់ខ្សោយ ហើយប្រាក់ចំណូលក្នុងគ្រួសារត្រូវតាមលក្ខណវិនិច្ឆ័យដូចខាងក្រោមនេះ៖

- មកដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣៖ ៦០.០០០$ បន្ថែម ១២.០០០$ សម្រាប់សមាជិកក្នុងគ្រួសារម្នាក់ៗ
- ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៣ ដល់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤៖ ៧៥.០០០$ បន្ថែម ១៥.០០០$ សម្រាប់សមាជិកក្នុងគ្រួសារម្នាក់ៗ
- ចំពោះសិស្សានុសិស្សដែលពិការ នឹងមានការសម្រួលថែមទៀតសម្រាប់ប្រាក់ឧបត្ថម្ភ ដែលត្រូវអនុលោមទៅតាមច្បាប់។

ក្រសួងអប់រំនៃរដ្ឋពិនស៊ីលវេញ៉ា នឹងបោះពុម្ពបញ្ជីឈ្មោះសាលាបឋមសិក្សាដែលមានចំណាត់ថ្នាក់ក្រោម១៥ភាគរយ និងសាលាមធ្យមសិក្សាដែលមានចំណាត់ថ្នាក់ក្រោម១៥ភាគរយ ដោយយោងទៅលើពិន្ទុសរុបនៃ គណិតវិទ្យា និងការអាន នៃការប្រឡង PSSA ប្រចាំឆ្នាំ ហើយចាត់ទុកសាលាទាំងនោះថាជាសាលាដែលអន់ខ្សោយ។

**ចំនួនទឹកប្រាក់នៃអាហារូបករណ៍៖** ចំនួនទឹកប្រាក់នៃអាហារូបករណ៍ច្រើនបំផុត ដែលគេផ្តល់ឲ្យសិស្សដែលមានសិទ្ធិ មានដូចតទៅ៖

- សិស្សមិនពិការ ៨.៥០០$
- សិស្សពិការ ១៥.០០០$

**ការខូបត្ថម្ភ៖** អាហារូបករណ៍នេះ ឧបត្ថម្ភដោយក្រុមហ៊ុនដែលធ្វើវិភាគទានទៅឲ្យអង្គការដែលផ្តល់អាហារូបករណ៍ ដើម្បីជាការប្តូរនិងការទារថ្លៃបង់ពន្ធមកវិញ។ ចំនួនទឹកប្រាក់នៃអាហារូបករណ៍មិនអាចលើសពីចំនួននៃវិភាគទានដែលក្រុមហ៊ុនផ្តល់ឲ្យអង្គការផ្នែកអាហារូបករណ៍បានទេ។ ទោះជាសិស្សមានសិទ្ធិអាចទទួលអាហារូបករណ៍ក៏ដោយ អាហារូបករណ៍នោះអាស្រ័យទៅលើប្រាក់ដែលមាន។

**សេចក្តីតម្រូវ៖** អាហារូបករណ៍អាចប្រើសម្រាប់បង់ថ្លៃសាលា និងថ្លៃផ្សេងៗដែលទាក់ទងនឹងសាលា នៅសាលាឯកជនដែលចូលរួមក្នុងកម្មវិធីនេះ ឬអ្នកមិនរស់នៅក្នុងព្រំដែននៃសាលារបស់ក្រសួងអប់រំ តែប៉ុណ្ណោះ។ គេនឹងមិនផ្តល់អាហារូបករណ៍សម្រាប់ការចុះឈ្មោះក្នុងកម្មវិធីអប់រំនៅផ្ទះទេ។ ចំនួនទឹកប្រាក់សារុប នៃអាហារូបករណ៍ និងប្រាក់ជំនួយបន្ថែម មិនអាចលើសពីថ្លៃសាលា និងថ្លៃផ្សេងៗដែលទាក់ទងនឹងសាលាដែលចូលរួមក្នុងកម្មវិធីនេះ បានទេ។ អាហារូបករណ៍ដែលមាតាបិតាទទួល គេមិនរាប់ថាជាប្រាក់ចំណូលដែលត្រូវបង់ពន្ធទេ។ សាលាឯកជន ឬសាលារដ្ឋដែលចូលរួមក្នុងកម្មវិធីនេះ មិនអាចទារថ្លៃសាលាលើសពីថ្លៃសម្រាប់សិស្សានុសិស្សដែលមិនចូលរួមក្នុងកម្មវិធីនេះ បានទេ។

**យានជំនិះ៖** ក្រសួងអប់រំដែលផ្តល់យានជំនិះដល់សិស្សានុសិស្សដែលរស់នៅក្នុងតំបន់ ត្រូវផ្តល់យានជំនិះដល់សិស្សដែលទៅរៀននៅសាលាឯកជនដែលចូលរួមក្នុងកម្មវិធីនេះ ដែលស្ថិតនៅក្នុងចម្ងាយ១៦គីឡូម៉ែត្រ នៃព្រំដែនតំបន់រស់នៅរបស់ក្រសួងអប់រំ។ ក្រសួងអប់រំដែលផ្តល់យានជំនិះដល់សិស្សានុសិស្សដែលរស់នៅក្នុងតំបន់ ត្រូវផ្តល់យានជំនិះដល់សិស្សដែលទៅរៀននៅសាលារដ្ឋនៅក្រៅតំបន់របស់ខ្លួនរស់នៅដែលស្ថិតនៅក្នុងចម្ងាយ១៦គីឡូម៉ែត្រ នៃព្រំដែនតំបន់រស់នៅរបស់ក្រសួងអប់រំ។

**វិធីដាក់ពាក្យសុំអាហារូបករណ៍៖** អាហារូបករណ៍ ផ្តល់ឲ្យដោយអង្គការដែលផ្តល់អាហារូបករណ៍ មិនមែនក្រសួងផ្នែកអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ច (Department of Community and Economic Development (DCED)) ឬ ក្រសួងអប់រំ នោះទេ។ បញ្ជីឈ្មោះអង្គការដែលផ្តល់អាហារូបករណ៍មាននៅក្នុង វិបសៃរបស់ DCED www.newpa.com/ostc។ បណ្តាញតភ្ជាប់នេះ ផ្តល់ការណែនាំច្បាស់លាស់អំពីរបៀបទាក់ទងទៅអង្គការដែលផ្តល់អាហារូបករណ៍។ អង្គការដែលផ្តល់អាហារូបករណ៍នឹងផ្តល់ព័ត៌មានលម្អិត អំពីវិធីដាក់ពាក្យសុំអាហារូបករណ៍របស់ពួកគេ។ មាតាបិតាគប្បីសហការជាមួយ អង្គការដែលផ្តល់អាហារូបករណ៍ ដើម្បីចូលរួមក្នុងកម្មវិធីនេះ មិនមែនជាមួយ DCED ទេ។

**ការផ្តល់អាហារូបករណ៍៖** ក្នុងការផ្តល់អាហារូបករណ៍ អង្គការដែលផ្តល់អាហារូបករណ៍ គប្បីផ្តល់ឲ្យជាមុនដល់បេក្ខជនដែលមានសិទ្ធិ ដែល៖

- ទទួលអាហារូបករណ៍កាលពីឆ្នាំសិក្សាមុន
- មានប្រាក់ចំណូលតាមកម្រិតដែលបានកំណត់ ឬ
- មានប្រាក់ចំណូលតាមកម្រិតដែលបានកំណត់ ហើយរស់នៅក្នុងក្រសួងអប់រំ first class គឺជាក្រសួងដែលមានមធ្យមភាគសមាជិកប្រចាំថ្ងៃលើសពី ៧.៥០០ នាក់ ដែលទទួលប្រាក់ជំនួយជាមុន សម្រាប់មូលដ្ឋាននៃការអប់រំ ឬក្រសួងដែលបានទទួលប្រាក់ជំនួយជាមុនសម្រាប់មូលដ្ឋាននៃការអប់រំ ហើយមានសេចក្តីប្រកាសថាខ្វះខាតថវិកា ក្រោមមាត្រាលេខ៦៩១ នៃច្បាប់សាលារដ្ឋ ឬចូលរួមក្នុងការប្តឹងផ្តល់រដ្ឋ ដែលក្រសួងអប់រំសុំប្រាក់ជំនួយ ដើម្បីអាចឲ្យក្រសួងអប់រំបន្តដំណើរការបាន។

**ការទទួលខុសត្រូវរបស់មាតាបិតា៖** តាមកម្មវិធីនេះ មាតាបិតាត្រូវទទួលខុសត្រូវក្នុងការទាក់ទង និងការចុះឈ្មោះកូនរបស់គាត់ក្នុងសាលារដ្ឋ ឬសាលាឯកជន ដែលចូលរួមក្នុងកម្មវិធីនេះ។

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវិបសៃ៖ www.philasd.org/language/khmer